# ត្រូវការជំនួយក្នុងការបង់ប្រាក់កម្ចីទិញផ្ទះរបស់អ្នកមែនទេ?

## ថវិកាជំនួយម្ចាស់ផ្ទះរដ្ឋ Massachusetts គឺនៅទីនេះ។

## អំពី MASS HAF

ថវិកាជំនួយម្ចាស់ផ្ទះរដ្ឋម៉ាសាជូសេត (Massachusetts Homeowner Assistance Fund, Mass HAF) គឺមានសម្រាប់ផ្តល់ជូនដល់ម្ចាស់ផ្ទះដែលខកខានក្នុងការបង់កម្ចីរបស់ពួកគេដោយសារតែជំងឺរាតត្បាត COVID-19 ។ ប្រសិនបើត្រូវបានឯកភាព ក្រុមគ្រួសារមានសិទ្ធិទទួលបានជំនួយរហូតដល់ 50,000 ដុល្លារ។ គោលដៅរបស់ HAF គឺដើម្បីបង្ការការដកហូតទ្រព្យសម្បត្តិវិញ និងការបណ្តេញចេញនូវម្ចាស់ផ្ទះដែលមានសិទ្ធិទទួលបានជំនួយ។ Mass HAF គឺត្រូវបានផ្តល់ថវិកាដោយច្បាប់ស្តីពីផែនការសង្គ្រោះពលរដ្ឋអាមេរិក (American Rescue Plan Act, ARPA)។

Mass HAF នឹងមិនទទួលយកពាក្យស្នើសុំថ្មីបន្តទៀត បន្ទាប់ពី**ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023**។

កម្មវិធីជំនួយលំនៅដ្ឋានសម្រាប់គ្រួសារក្នុងអន្តរកាល (RAFT) ដែលផ្តល់មូលនិធិដោយរដ្ឋ នឹងមានផ្តល់ជូនចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2023 សម្រាប់ម្ចាស់ផ្ទះដែលមានចំណូលទាបដែលប្រឈមនឹងហានិភ័យនៃការរឹបអូសអចលនវត្ថុ។ នៅពេលនោះ ម្ចាស់ផ្ទះដែលមានសិទ្ធិអាចដាក់ពាក្យស្នើសុំសម្រាប់ RAFT តាមរយៈ **វិបផតថលជំនួយការទូទាត់លំនៅដ្ឋានបន្ទាន់** របស់នាយកដ្ឋានលំនៅដ្ឋាន និងអភិវឌ្ឍន៍សហគមន៍។

### អ្នកអាចនឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបាន Mass HAF ប្រសិនបើ៖

- ✓ អ្នកជាម្ចាស់កម្មសិទ្ធិ និងរស់នៅក្នុងខុនដូ ផ្ទះគ្រួសារទោល ឬអចលនទ្រព្យគ្រួសារ 2- 3- ឬ 4 ខ្នង នៅក្នុងរដ្ឋ Massachusetts
- ✓ អ្នកខកខានក្នុងការបង់ប្រាក់កម្ចីទិញផ្ទះរបស់អ្នក យ៉ាងតិច 3 ខែ
- ✓ អ្នក ឬនរណាម្នាក់នៅក្នុងគ្រួសាររបស់អ្នកមាន ប្រាក់ចំណូលទាបជាងមុន ឬថ្លៃចំណាយលើការរស់នៅ មានការកើនឡើង បន្ទាប់ពីថ្ងៃទី 21 ខែមករា ឆ្នាំ 2020 ដោយសារតែជំងឺរាតត្បាត COVID-19 ។ ករណីនេះរួមមាន ការបាត់បង់ការងារ ម៉ោងធ្វើការតិចជាងមុន ការចំណាយច្រើនជាងមុន លើការថែទាំក្មេង ជំងឺ ឬមិនអាចធ្វើការបានដោយសារតែអ្នកចាំបាច់ត្រូវមើលថែសមាជិកគ្រួសារ
- ✓ អ្នកបំពេញតាម ដែនកំណត់ប្រាក់ចំណូលរបស់កម្មវិធី (ដែនកំណត់ប្រាក់ចំណូលគឺ 150% នៃ AMI - ប្រាក់ចំណូល ជាមធ្យមក្នុងតំបន់)

### ចុះបើខ្ញុំជំពាក់ច្រើនជាង 50,000 ដុល្លារ?

**Mass HAF នឹងបង់រហូតដល់ 50,000** ដុល្លារ ហើយ ក្រុមហ៊ុនទារបំណុលរបស់អ្នក អាចនឹងផ្តល់ជាផែនការមួយដើម្បីជួយអ្នកក្នុងការបង់បរិមាណទឹកប្រាក់នៅសល់ដែលអ្នកជំពាក់។ ក្រុមហ៊ុនទារបំណុលរបស់អ្នក គឺជានរណាដែលអ្នកបង់ប្រាក់កម្ចីទៅកាន់។

### តើ MASS HAF អាចជួយខ្ញុំបានដោយរបៀបណា?

ប្រសិនបើអ្នកត្រូវបានអនុញ្ញាតសម្រាប់ Mass HAF អ្នកនឹងទទួលបានជំនួយដើម្បីបង់ប្រាក់កម្ចីដែលហួសកាលកំណត់។ ប្រសិនបើអ្នកមានការបង់ប្រាក់ពន្ធអចលនទ្រព្យ ធានារ៉ាប់រង ឬថ្លៃម្ចាស់កម្មសិទ្ធិ/ខុនដូ ដែលហួសកាលកំណត់ អ្នកអាចនឹងមានលទ្ធភាពទទួលបានជំនួយបន្ថែម។

### តើខ្ញុំនឹងទទួលបានលុយដោយផ្ទាល់ដែរឬទេ

**ទេ។** ប្រសិនបើអ្នកទទួលបានការអនុញ្ញាត លុយនឹងត្រូវបានបង់ដោយផ្ទាល់ទៅកាន់ក្រុមហ៊ុនទារបំណុលប្រាក់កម្ចីទិញផ្ទះរបស់អ្នក (ក្រុមហ៊ុនដែលទទួលការបង់ប្រាក់កម្ចីទិញផ្ទះរបស់អ្នក)។ អ្នកនឹងទទួលបានការជូនដំណឹងអំពីបរិមាណទឹកប្រាក់ជំនួយដែលត្រូវបានផ្តល់ជូន និងថាតើទឹកប្រាក់នោះត្រូវបានបង់ទៅលើអ្វី។

### តើខ្ញុំនឹងចាំបាច់ត្រូវសងប្រាក់នោះត្រឡប់ទៅវិញដែរឬទេ?

**ទេ** ជំនួយគឺជាអំណោយ មិនមែនជាឥណទានទេ។ អ្នកនឹងមិនចាំបាច់សងប្រាក់នោះត្រឡប់មកវិញទេ។

## តើខ្ញុំត្រូវដាក់ពាក្យស្នើសុំដោយរបៀបណា?

ការដាក់ពាក្យសុំគឺធ្វើឡើងតាមរយៈអនឡាញ។ ស្វែងយល់បន្ថែម និងដាក់ពាក្យស្នើសុំ ដោយចូលទៅកាន់ **massmortgagehelp.org**។ អ្នកក៏អាចបំពេញការត្រួតពិនិត្យខ្លីតាមអនឡាញបានផងដែរ ដើម្បីដឹងថាតើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានដែរឬអត់។

Mass HAF នឹងមិនទទួលយកពាក្យស្នើសុំថ្មីបន្តទៀត បន្ទាប់ពី**ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023**។

កម្មវិធីជំនួយលំនៅដ្ឋានសម្រាប់គ្រួសារក្នុងអន្តរកាល (RAFT) ដែលផ្តល់មូលនិធិដោយរដ្ឋ នឹងមានផ្តល់ជូនចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2023 សម្រាប់ម្ចាស់ផ្ទះដែលមានចំណូលទាបដែលប្រឈមនឹងហានិភ័យនៃការរឹបអូសអចលនវត្ថុ។ នៅពេលនោះ ម្ចាស់ផ្ទះដែលមានសិទ្ធិអាចដាក់ពាក្យស្នើសុំសម្រាប់ RAFT តាមរយៈ **វិបផតថលជំនួយការទូទាត់លំនៅដ្ឋានបន្ទាន់ .**

សម្រាប់ព័ត៌មានទូទៅអំពី Mass HAF ឬការធ្វើបច្ចុប្បន្នភាពអំពីស្ថានភាពពាក្យស្នើសុំរបស់អ្នក សូមធ្វើការហៅទៅកាន់មជ្ឈមណ្ឌលហៅទូរស័ព្ទ HAF តាមរយៈលេខ (833) 270 – 2953 ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 10 ព្រឹក រហូតដល់ម៉ោង 8 យប់ (មានសេវាកម្មសម្រាប់តម្រូវការអ្នកបកប្រែ)។ អ្នកក៏អាចធ្វើការជាមួយទីភ្នាក់ងារប្រឹក្សាយោបល់លំនៅដ្ឋានមិនរកប្រាក់ចំណេញ ដែលអាចជួយអ្នកក្នុងការដាក់ពាក្យស្នើសុំ។ បញ្ជីនៃទីភ្នាក់ងារប្រឹក្សាយោបល់លំនៅដ្ឋានអាចរកបាននៅលើ **www.massmortgagehelp.org**

ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់កំពុងជួបប្រទះវិបត្តិសុខភាពផ្លូវចិត្ត និង/ឬមានគំនិតចង់ធ្វើអត្តឃាត សូមទូរស័ព្ទឬផ្ញើសារទៅលេខ 988 ដែលជាលេខសម្រាប់អន្តរាគមន៍ការធ្វើអត្តឃាតនិងការជួបវិបត្តិថ្នាក់ជាតិ។ បណ្តាញទូរស័ព្ទជំនួយ 988 សម្រាប់អន្តរាគមន៍ការធ្វើអត្តឃាតនិងការជួបវិបត្តិមាន 24ម៉ោង ក្នុងមួយថ្ងៃ និង 7ថ្ងៃ ក្នុងមួយសប្តាហ៍។ អ្នកក៏អាចចូលប្រើមុខងារជជែកដែលមានផងដែរនៅលើគេហទំព័រ : **https://988lifeline.org/contact-the-lifeline/**

ប្រសិនបើអ្នកកំពុងស្វែងរកអ្នកជំនាញដែលមានវិជ្ជាជីវៈសម្រាប់ការវាយតម្លៃសុខភាពផ្លូវចិត្ត និង/ឬការបញ្ជូនសម្រាប់សុខភាពផ្លូវចិត្ត សូមទាក់ទងបណ្តាញជំនួយសុខភាពអាកប្បកិរិយារបស់រដ្ឋម៉ាសាឈូសេត ដោយទូរស័ព្ទឬផ្ញើសារទៅលេខ 833-773-2445 (BHHL)។ បណ្តាញទូរស័ព្ទជំនួយមាន 24ម៉ោង ក្នុងមួយថ្ងៃ និង 7ថ្ងៃ ក្នុងមួយសប្តាហ៍។ អ្នកក៏អាចចូលប្រើមុខងារជជែកដែលមានផងដែរនៅលើគេហទំព័រ៖ **https://www.masshelpline.com/contact/**

Khmer

**massmortgagehelp.org**

គម្រោងនេះត្រូវបានគាំទ្រទាំងស្រុង ឬដោយផ្នែក ដោយសេចក្តីសម្រេចផ្តល់ជូនរបស់សហព័ន្ធលេខ HAF0174 ដែលត្រូវបានផ្តល់ជូ Massachusetts សេតដោយក្រសួងរតនាគារសហរដ្ឋអាមេរិក។